# លិខិតជាសាធារណៈទទូចឲ្យមានការស៊ើបអង្កេតជាបន្ទាន់
# ទៅលើការបាត់ខ្លួនរបស់ ខឹម សុផាត

ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៤ - យើងខ្ញុំជាក្រុមសង្គមស៊ីវិលដែលមានរាយនាមដូចខាងក្រោម មានការព្រួយបារម្ភយ៉ាង ខ្លាំងចំពោះការបាត់ខ្លួនក្មេងប្រុសឈ្មោះ ខឹម សុផាត អាយុ ១៦ឆ្នាំ ដែលបានបាត់ខ្លួន ចាប់តាំងពីមានការបង្ក្រាបយ៉ាងហិង្សាដោយកងសន្តិសុខរបស់អាជ្ញាធររដ្ឋ មកលើកម្មកររោងចក្រដែលធ្វើការតវ៉ា កាលពីថ្ងៃទី៣ ខែមករា ឆ្នាំ២០១៤ នៅក្បែរសួនឧស្សាហកម្មកាណាឌីយ៉ា តាមបណ្តោយផ្លូវវេងស្រេង ក្នុងរាជធានីភ្នំពេញ។ យើងខ្ញុំសូមអំពាវនាវដល់រាជរដ្ឋាភិបាលកម្ពុជា សូមមេត្តាចាត់នូវគ្រប់វិធានការសមស្របទាំងអស់ជាបន្ទាន់ ដើម្បីធ្វើការស៊ើបអង្កេតឲ្យបានហ្មត់ចត់ និងអព្យាក្រឹត្យ ទៅលើការបាត់ខ្លួនរបស់ ខឹម សុផាត ហើយជូនដំណឹងទៅក្រុមគ្រួសាររបស់គាត់អំពីជោគវាសនា ឬទីកន្លែងដែលគាត់កំពុងស្នាក់នៅផង។

ការបង្ក្រាបដែលបានចាប់ផ្តើមនៅថ្ងៃទី២ ខែមករា ឆ្នាំ២០១៤ បណ្តាលឲ្យមនុស្សយ៉ាងតិច ៤ នាក់ ត្រូវបានសម្លាប់ រងរបួសជាច្រើននាក់ ហើយកម្មករនិងអ្នកការពារសិទ្ធិមនុស្សចំនួន២៣ នាក់ត្រូវបានចាប់ខ្លួន។ ខឹម សុផាត ត្រូវបានគេឃើញជាលើកចុងក្រោយ កាលពីព្រឹកថ្ងៃទី៣ ខែមករា ឆ្នាំ២០១៤ ដោយដួលលើដីលើផ្លូវវេងស្រេង និងមានឈាមហូរចេញពីទ្រូង ដែលហាក់ដូចជាត្រូវគេបាញ់ចំទ្រូង។ ជាងពីរខែក្រោយមក នៅតែមិនមានដំណឹងពី សុផាត ដដែល។

រាជរដ្ឋាភិបាលកម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញាអន្តរជាតិស្តីពីការការពារជនគ្រប់រូបពីការបាត់ខ្លួនដោយបង្ខំ (ICCPED) កាលពីថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៣ ហេតុដូចនេះហើយ រដ្ឋជាភាគីមានកាតព្វកិច្ចអនុវត្តទៅតាមលក្ខខណ្ឌនៃអនុសញ្ញានេះ។ យោងតាមមាត្រា ២ នៃអនុសញ្ញានេះ (ICCPED) ការបាត់ខ្លួនដោយបង្ខំកើតឡើង ប្រសិនបើបុគ្គលម្នាក់ត្រូវបានគេដកហូតសិទ្ធិសេរីភាពរបស់ខ្លួន ក្រោមគ្រប់រូបភាពធ្វើឡើងដោយភ្នាក់ងាររដ្ឋ ឬដោយបុគ្គលដែលមានការអនុញ្ញាត ការគាំទ្រ ឬយល់ព្រមពីរដ្ឋ ហើយលុះក្រោយមក បដិសេធមិនទទួលស្គាល់ពីការដកហូតសិទ្ធិសេរីភាព ឬដោយមានការលាក់បំបាំងពីទីកន្លែងជនបាត់ខ្លួននោះ។

នៅថ្ងៃមានការបាញ់ប្រហារនោះ មិត្តភក្តិនិងជាអ្នករួមការងារម្នាក់បានឃើញសុផាតដួលលើដី ដោយមានរបួសយ៉ាងធ្ងន់ធ្ងរត្រង់ដើមទ្រូងរបស់គាត់។ នៅខណៈដែលអ្នកមួយចំនួននៅក្បែរនោះបានព្យាយាមជួយសុផាត អ្នកទាំងនោះបានឮសុផាតទទូចឲ្យពួកគាត់ឈប់ជួយគាត់ ហើយជួយខ្លួនឯងជាមុនទៅ ដោយនិយាយថាគាត់ "នឹងមិនរស់ទេ"។ ពេលនោះការបាញ់ប្រហារមកលើប្រជាពលរដ្ឋកំពុងបន្ត។ អ្នកដែលបានព្យាយាមជួយសុផាត រួមទាំងសាក្សីដែលឃើញផ្ទាល់ភ្នែក

ផងបានរត់រកកន្លែងលាក់ខ្លួន ហើយសាក្សីម្នាក់នោះក៏បានត្រូវគ្រាប់កាំភ្លើង ដោយមិនបានទទួលការព្យាបាលរហូតដល់ល្ងាចថ្ងៃនោះ។

ដោយពិចារណាលើរបាយការណ៍របស់សាក្សី និងការបាត់ខ្លួនរបស់សូផាតមិនដឹងជានៅទីណា ក្នុងបរិបទនៃការបាញ់ប្រហារ និងការចាប់ខ្លួនដោយខុសច្បាប់ដោយកងសន្តិសុខរបស់កម្ពុជានាថ្ងៃនោះ គឺមានមូលហេតុសមស្របគួរឲ្យជឿបានថា សូផាត ប្រហែលជាបាត់ខ្លួនដោយបង្ខំ។ ប៉ុន្តែមកទល់ពេលនេះ អាជ្ញាធរបានបដិសេធថាខ្លួនមិនបានដឹងពីជោគវាសនាឬកន្លែង លាក់ខ្លួនរបស់សូផាតនោះទេ ហើយមិនបានធ្វើការស៊ើបអង្កេតណាមួយលើករណីនេះឡើយ។

ការបាត់ខ្លួនដោយបង្ខំ គឺជាការរំលោភធ្ងន់ធ្ងរលើសិទ្ធិមនុស្ស រួមមាន៖ ការហាមឃាត់ការធ្វើទារុណកម្មនិងអំពើឃោរឃៅ ភាពអមនុស្សធម៌ ឬការធ្វើបាប សិទ្ធិមានសេរីភាពនិងសន្តិសុខបុគ្គល សិទ្ធិក្នុងជីវិតគ្រួសារ សិទ្ធិក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌និងជាសាធារណៈ និងនៅក្នុងករណីដែលបុគ្គលត្រូវបានគេសម្លាប់ គឺសិទ្ធិរស់រានមានជីវិត។

លើសពីការហាមឃាត់ស្តីពីការបង្ខំឲ្យមានការបាត់ខ្លួន អនុសញ្ញា ICCPED ក៏បានបង្កើតកាតព្វកិច្ចសម្រាប់រដ្ឋ ក្នុងការចាត់នូវវិធានការសមស្របមួយចំនួន ដើម្បីធ្វើការស៊ើបអង្កេតស្ថានភាព ដែលមានមូលហេតុសមស្របគួរជឿជាក់ថា មានការបាត់ខ្លួនដោយបង្ខំបានកើតឡើង ហើយនាំយកអ្នកទទួលខុសត្រូវមកផ្តន្ទាទោសព្រហ្មទណ្ឌ ទោះជាមានឬមិនមានពាក្យបណ្តឹងជាផ្លូវការត្រូវបានដាក់ក៏ដោយ[1]។ លើសពីនេះទៅទៀត រដ្ឋត្រូវតែ "ចាត់នូវគ្រប់វិធានការនានាដើម្បីស្វែងរកកំណត់ទីតាំង និងដោះលែងអ្នកដែលបាត់ខ្លួន ហើយប្រសិនបើស្លាប់ត្រូវកំណត់ទីតាំង គោរព និងបញ្ជូនសាកសពត្រឡប់មកវិញ"។[2]

ប៉ុន្តែរាជរដ្ឋាភិបាលកម្ពុជាមិនបានធ្វើការស៊ើបអង្កេតលើករណីការបាត់ខ្លួន ខឹម សូផាត ឬករណីនៃការប្រើប្រាស់កងកម្លាំងច្រើនហួសហេតុ ពីសំណាក់កងសន្តិសុខជាច្រើននោះទេ។ ផ្ទុយទៅវិញនៅថ្ងៃទី៧ ខែមករា ឆ្នាំ២០១៤ លោកឧត្តមសេនីយត្រី ខេង ទិត្យ បានអះអាងថា គ្រប់ការស៊ើបអង្កេតនឹងផ្តោតទៅលើ "អ្នកញុះញង់មួយចំនួន" ជាជាងលើកងរាជអាវុធហត្ថ។[3] រហូតមកដល់ពេលនេះ មិនទាន់មានលទ្ធផលនៃការស៊ើបអង្កេតណាមួយ ត្រូវបានបង្ហាញជាសាធារណៈនោះទេ។ លើសពីនេះទៅទៀត កាលពីថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០១៤ លោកឧត្តមសេនីយត្រីដដែលបានប្រាប់វិទ្យុសំឡេងសហរដ្ឋអាមេរិកជាភាសាខ្មែរថា ខឹម សូផាត មិនស្ថិតនៅក្នុងចំណោមមនុស្សដែលត្រូវបានចាប់ខ្លួននោះទេ (ជាអ្វីដែលអ្នកឃ្លាំមើលការរំលោភសិទ្ធិមនុស្ស និងអ្នកកាសែតជា

[1] សូមមើលអនុសញ្ញាអន្តរជាតិស្តីពីការការពារគ្រប់បុគ្គលពីការបាត់ខ្លួនដោយបង្ខំ (ICCPED), មាត្រា១២ (២)

[2] អនុសញ្ញាអន្តរជាតិ ICCPED មាត្រា២៤(៣)

[3] The Cambodia Daily, *No Results in Protest Shooting Investigations,* 04 February 2014

ច្រើនបានដឹងរួចហើយកាលពីប៉ុន្មានសប្ដាហ៍មុន) ហើយជំរុញឲ្យក្រុមគ្រួសារធ្វើការដាក់ពាក្យបណ្ដឹងទៅកាន់តុលាការ។[4]

សមាគមអាដហុកការពារសិទ្ធិមនុស្សនិងអភិវឌ្ឍន៍នៅកម្ពុជា (ADHOC) និងអង្គការសម្ព័ន្ធខ្មែរជំរឿននិងការពារសិទ្ធិមនុស្សលីកាដូ (LICADHO) បានធ្វើការស៊ើបអង្កេតផ្ទាល់ខ្លួនស្វែងរក ខឹម សូផាត ប៉ុន្តែរហូតមកដល់ពេលនេះមិនទាន់ដឹងថា សូផាត នៅទីណានោះទេ។ ឥឡូវនេះ ក្រុមគ្រួសាររបស់ សូផាត សន្មត់ថា សូផាត បានស្លាប់ទៅហើយ។

ដោយយោងតាមកាតព្វកិច្ចរបស់ខ្លួនក្រោមអនុសញ្ញាអន្តរជាតិ ICCPED រាជរដ្ឋាភិបាលកម្ពុជា គួរតែធ្វើការស៊ើបអង្កេតជាបន្ទាន់ដោយហ្មត់ចត់ និងមិនលំអៀងទៅលើករណីរបស់ ខឹម សូផាត ដែលបានបាត់ខ្លួនដោយបង្ខំ។ ជាងនេះទៀត សមាជិកគ្រួសារមានសិទ្ធិក្នុងការដឹងនូវការពិតពាក់ព័ន្ធនឹងស្ថានភាពនៃការបាត់ខ្លួនដោយបង្ខំ ដំណើរការ និងលទ្ធផលនៃការស៊ើបអង្កេតហើយ និងជោគវាសនា ឬទីកន្លែងដែលសូផាតកំពុងនៅ។[5] ប្រសិនបើរកឃើញថា ខឹម សូផាត គឺជាជនរងគ្រោះនៃការបាត់ខ្លួនដោយបង្ខំ តាមអនុសញ្ញា ICCPED នោះបានចែងច្បាស់លាស់ថាអ្នកដែលសង្ស័យថាជាអ្នកទទួលខុសត្រូវ ត្រូវតែបានផ្តន្ទាទោស។ ហើយជនរងគ្រោះ មានសិទ្ធិទទួលការជួសជុលសំណងភ្លាមៗដោយយុត្តិធម៌ និងគ្រប់គ្រាន់ ការប្រគល់សងវិញ ការស្តារនីតិ-សម្បទា ការធ្វើឲ្យពេញចិត្ត និងការធានាថានឹងមិនមានការប្រព្រឹត្តិបែបនេះឡើងវិញនោះទេ ដោយមានការទទួលស្គាល់ពីរាជរដ្ឋាភិបាលកម្ពុជា នូវការបង្កើតគណៈកម្មាធិការស្តីពីការបាត់ខ្លួនដោយបង្ខំ ក្នុងការទទួលបាន និងពិចារណាលើទំនាក់ទំនងជាមួយ ឬក្នុងនាមជនរងគ្រោះ និងរដ្ឋជាភាគីដទៃទៀត។

លិខិតនេះគ្រាំទ្រដោយ ក្រុមសង្គមស៊ីវិល ជាតិ និងអន្តរជាតិ ចំនួន៥៤ ដែលមានរាយនាមដូចខាងក្រោម៖

1. Amnesty International
2. Asia Pacific Forum on Women, Law and Development (APWLD)
3. Asian Forum for Human Rights and Development (FORUM-ASIA)
4. Banteay Srey
5. Boeung Kak Lake Community (BKL)
6. Borei Keila Community (BK)
7. Building and Wood Workers Trade Union Federation of Cambodia (BWTUC)
8. CamASEAN Youth's Future (CamASEAN)
9. Cambodia's Independent Civil-Servants Association (CICA)
10. Cambodian Alliance of Trade Unions (CATU)
11. Cambodian Center for Human Rights (CCHR)
12. Cambodian Center for Independent Media (CCIM)

[4] វីឌេអូភាសាខ្មែរ ក្មេងប្រុសដែលបាត់ខ្លួនត្រូវបានសន្មត់ថាបានស្លាប់បន្ទាប់ពីការបាញ់ប្រហារលើបាតុកម្ម ថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០១៤

[5] សូមមើលអនុសញ្ញា ICCPED មាត្រា ២៤ (២)

13. Cambodian Confederation Unions (CCU)
14. Cambodian Domestic Worker Network (CDWN)
15. Cambodian Food and Service Worker Federation (CFSWF)
16. Cambodian Human Rights Action Committee (CHRAC)
17. Cambodian Human Rights and Development Association (ADHOC)
18. Cambodian Independent Teachers Association (CITA)
19. Cambodian Labour Confederation (CLC)
20. Cambodian League for the Promotion and Defense of Human Rights (LICADHO)
21. Cambodian Tourism and Service Workers Federation (CTSWF)
22. Cambodian Worker Center for Development (CWCD)
23. Cambodian Youth Network (CYN)
24. Civil Rights Defenders
25. Coalition of Cambodian Apparel Workers Domestic Unions (C.CAWDU)
26. Coalition of Cambodian Employee Workers of Industry and Service Union (CEWISU)
27. Coalition of Cambodian Farmer Community (CCFC)
28. Committee to Promote Women in Politics (CPWP)
29. Community Legal Education Centre (CLEC)
30. Community Peace-Building Network (CPN)
31. Equitable Cambodia (EC)
32. Farmer Development Association (FDA)
33. Farmers Association for Peace and Development (FAPD)
34. Gender and Development for Cambodia (GADC)
35. Housing Rights Task Force (HRTF)
36. Human Rights Watch
37. Independent Democracy of Informal Economy Association (IDEA)
38. Independent Monk Network for Social Justice (IMNSJ)
39. IndustriALL Global Union
40. International Federation for Human Rights (FIDH)
41. International Trade Union Confederation (ITUC)
42. Labour Behind the Label
43. LICADHO Canada
44. Messenger Band (MB)
45. Neutral and Impartial Committee for Free and Fair Election in Cambodia (NICFEC)
46. Sahmakum Teang Tnaut (STT)
47. Solidarity Center
48. The Cambodian Committee for Women (CAMBOW)
49. The Cambodian NGO Committee on CEDAW (NGO-CEDAW)
50. Thmar Kol Community
51. UNI Global Union
52. UNISON
53. War on Want
54. Worker Rights Consortium (WRC)